**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមុខងារសាធារណៈ** **ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

លេខ: ២៥៧ មស.សហវន

# សេចក្តីណែនាំ
## ស្តីពី
## ការពង្រឹងការប្រើប្រាស់និងការបើកផ្តល់ប្រាក់កម្រៃ ដល់មន្ត្រីជាប់កិច្ចសន្យានិងបុគ្គលិកអណ្តែត

យោងសេចក្តីជូនដំណឹងលេខ១៥៧៤ សជណ.សរ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីលទ្ធផលនៃសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៤ និងចំណារដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៥ លើលិខិតលេខ៥១៥ សហវ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៥ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្នុងគោលបំណងពង្រឹងប្រសិទ្ធភាពគ្រប់គ្រងការប្រើប្រាស់និងការបើកផ្តល់ប្រាក់កម្រៃមន្ត្រីជាប់កិច្ចសន្យា និង បុគ្គលិកអណ្តែតប្រកបដោយការទទួលខុសត្រូវនិងគណនេយ្យភាពខ្ពស់ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ក្រសួងមុខងារសាធារណៈ សូមណែនាំដល់គ្រប់ក្រសួង ស្ថាប័ន សាលារាជធានី ខេត្ត មន្ទីរ និងអង្គភាពជំនាញជុំវិញរាជធានី ខេត្ត ដែលបានប្រើប្រាស់មន្ត្រីជាប់កិច្ចសន្យានិងបុគ្គលិកអណ្តែត ដូចខាងក្រោម៖

១. ក្រសួង ស្ថាប័ន សាលារាជធានី ខេត្ត មន្ទីរ និងអង្គភាពជំនាញជុំវិញរាជធានី ខេត្ត ត្រូវចាត់ចែងប្រើប្រាស់មន្ត្រីជាប់កិច្ចសន្យា និង បុគ្គលិកអណ្តែតឲ្យបានសមស្របតាមចំនួនដែលទទួលការអនុញ្ញាតពីរាជរដ្ឋាភិបាលនិងអនុលោមសេចក្តីជូនដំណឹងរបស់ក្រសួងមុខងារសាធារណៈ

២. ក្រសួង ស្ថាប័ន សាលារាជធានី ខេត្ត មន្ទីរ និងអង្គភាពជំនាញជុំវិញរាជធានី ខេត្ត ត្រូវចាត់ចែងឲ្យមន្ត្រីជាប់កិច្ចសន្យានិងបុគ្គលិកអណ្តែតម្នាក់ៗ បំពេញប្រវត្តិរូបសង្ខេបដូចមានជូនភ្ជាប់មកជាមួយសេចក្តីណែនាំនេះ

៣. ក្រសួង ស្ថាប័ន សាលារាជធានី ខេត្ត មន្ទីរ និងអង្គភាពជំនាញជុំវិញរាជធានី ខេត្ត ត្រូវចាត់ចែងឲ្យប្រធានអង្គភាពដែលគ្រប់គ្រងផ្ទាល់មន្ត្រីជាប់កិច្ចសន្យានិងបុគ្គលិកអណ្តែត បំពេញបញ្ជីឈ្មោះមន្ត្រីជាប់កិច្ចសន្យានិងបុគ្គលិកអណ្តែតជាលក្ខណៈរបបស្វ័យប្រកាស ផ្អែកលើចំនួនដែលប្រើប្រាស់ពិតប្រាកដនិងជាក់ស្តែងតាមគំរូបញ្ជីជូនភ្ជាប់មកជាមួយសេចក្តីណែនាំនេះ

៤. នាយកដ្ឋានបុគ្គលិកនៃក្រសួង ស្ថាប័ន ត្រូវបំពេញព័ត៌មានមន្ត្រីជាប់កិច្ចសន្យានិងបុគ្គលិកអណ្តែតរបស់ក្រសួង ស្ថាប័ន ដែលបំពេញការងារនៅថ្នាក់ជាតិក្នុងតារាងព័ត៌មានអេឡិចត្រូនិចដែលផ្តល់ដោយក្រសួងមុខងារសាធារណៈ

៥. ក្រសួង ស្ថាប័ន ត្រូវបញ្ជូនឯកសារដែលរួមមានប្រវត្តិរូបសង្ខេប បញ្ជីឈ្មោះមន្ត្រីជាប់កិច្ចសន្យានិងបុគ្គលិកអណ្តែត ព្រមទាំងតារាងអេឡិចត្រូនិចដែលបានបំពេញរួចមកក្រសួងមុខងារសាធារណៈ ឲ្យបានមុនថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៥

៦. សាលារាជធានី ខេត្ត មន្ទីរ និងអង្គភាពជំនាញជុំវិញរាជធានី ខេត្ត ត្រូវចាត់ចែងឲ្យប្រធានអង្គភាពដែលគ្រប់គ្រងផ្ទាល់មន្ត្រីជាប់កិច្ចសន្យានិងបុគ្គលិកអណ្តែត បំពេញបញ្ជីឈ្មោះមន្ត្រីជាប់កិច្ចសន្យានិងបុគ្គលិកអណ្តែតជាលក្ខណៈរបបស្វ័យប្រកាស ផ្អែកលើចំនួនដែលប្រើប្រាស់ពិតប្រាកដនិងជាក់ស្តែងតាមគំរូបញ្ជីជូនភ្ជាប់មកជាមួយសេចក្តីណែនាំនេះ


អាសយដ្ឋានៈ (កែងផ្លូវម៉ៃដាលេខ២០០៤) ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ ភ្នំពេញ ទូរស័ព្ទ.ទូរសារ(៨៥៥) ២៣ ៨៦៦ ៥០១

៧. មន្ទីរមុខងារសាធារណៈរាជធានី ខេត្ត ត្រូវចាត់ចែងប្រមូលឯកសាររួមមានប្រវត្តិរូបសង្ខេបនិងបញ្ជីឈ្មោះមន្ត្រីជាប់កិច្ចសន្យានិងបុគ្គលិកអណ្តែតនៃសាលារាជធានី ខេត្ត មន្ទីរ និងអង្គភាពជំនាញជុំវិញរាជធានី ខេត្ត និងត្រូវចាត់ចែងបញ្ចូលព័ត៌មានក្នុងតារាងអេឡិចត្រូនិចដែលផ្តល់ដោយក្រសួងមុខងារសាធារណៈ ព្រមទាំងត្រូវបញ្ជូនឯកសាររួមមានបញ្ជីឈ្មោះមន្ត្រីជាប់កិច្ចសន្យានិងបុគ្គលិកអណ្តែតនិងតារាងព័ត៌មានអេឡិចត្រូនិច ដែលបានបំពេញរួចមកក្រសួងមុខងារសាធារណៈ ឲ្យបានមុនថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៥ ព្រមទាំងថតចម្លងមួយច្បាប់ជូនដល់សាលារាជធានី ខេត្ត។ ដោយឡែក ប្រវត្តិរូបសង្ខេបរបស់មន្ត្រីជាប់កិច្ចសន្យានិងបុគ្គលិកអណ្តែតត្រូវរក្សាទុកនៅមន្ទីរមុខងារសាធារណៈរាជធានី ខេត្ត

៨. ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងផ្អាកការបើកផ្តល់ប្រាក់កម្រៃដល់មន្ត្រីជាប់កិច្ចសន្យានិងបុគ្គលិកអណ្តែតរបស់ក្រសួង ស្ថាប័ន សាលារាជធានី ខេត្ត មន្ទីរ និងអង្គភាពជំនាញជុំវិញរាជធានី ខេត្ត ដែលមិនបានបំពេញនិងផ្តល់សំណុំឯកសារតាមការតម្រូវក្នុងសេចក្តីណែនាំនេះ ចាប់ពីខែមេសា ឆ្នាំ២០១៥

៩. ក្រសួង ស្ថាប័ន ត្រូវចាត់ចែងការរៀបចំបើកគណនីសម្រាប់ការបើកផ្តល់ប្រាក់កម្រៃជូនមន្ត្រីជាប់កិច្ចសន្យានិងបុគ្គលិកអណ្តែតឲ្យបានរួចរាល់មុនដំណាច់ខែមិថុនា ឆ្នាំ២០១៥

១០.គ្រប់ក្រសួង ស្ថាប័ន សាលារាជធានីខេត្ត មន្ទីរ និងអង្គភាពជំនាញជុំវិញរាជធានី ខេត្ត ដែលប្រើប្រាស់មន្ត្រីជាប់កិច្ចសន្យានិងបុគ្គលិកអណ្តែតត្រូវមានគណនេយ្យភាព និងទទួលខុសត្រូវនូវរាល់ព័ត៌មាននិងចំនួនជាក់លាក់នៃការប្រើប្រាស់មន្ត្រីជាប់កិច្ចសន្យានិងបុគ្គលិកអណ្តែត។ ក្នុងករណីការធ្វើអធិការកិច្ចនៅពេលក្រោយ ពិនិត្យឃើញថា ការប្រកាសមានភាពមិនត្រឹមត្រូវ ប្រធានអង្គភាពគ្រប់គ្រងផ្ទាល់នោះ នឹងត្រូវទទួលទោសតាមច្បាប់ជាធរមាន។

ទទួលបានសេចក្តីណែនាំនេះ គ្រប់ក្រសួង ស្ថាប័ន សាលារាជធានី ខេត្ត មន្ទីរ និងអង្គភាពជំនាញជុំវិញសាលារាជធានី ខេត្ត ត្រូវទទួលខុសត្រូវនិងចាត់ចែងអនុវត្តឲ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។ ៚

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០១៥

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ**

**ពេជ្រ ប៊ុនធិន**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- អង្គភាពប្រឆាំងអំពើពុករលួយ
- សាលារាជធានី ខេត្ត
- មន្ទីរជំនាញរាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

គំរូ

**ក្រសួង ស្ថាប័ន :**..............................
**អង្គភាព:**..............................

រូបថត
(៤ x ៦)

## ប្រវត្តិរូបសង្ខេប

### ក.ព័ត៌មានផ្ទាល់ខ្លួន

- គោត្តនាមនិងនាម :..............................ភេទ:............សញ្ជាតិ:................
- អក្សរឡាតាំង :..............................................................................
- ថ្ងៃខែឆ្នាំកំណើត :..............................................................................
- ទីកន្លែងកំណើត :..............................................................................
..............................................................................
- កម្រិតវប្បធម៌ :..............................................................................
- លេខអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរឬលិខិតឆ្លងដែន:..................................................
- អង្គភាពបំពេញការងារ :..............................................................................
..............................................................................

### ខ.ព័ត៌មានទំនាក់ទំនង

- អាសយដ្ឋានបច្ចុប្បន្ន :..............................................................................
..............................................................................
- លេខទូរស័ព្ទ :..............................................................................
- អ៊ីម៉ែល (ប្រសិនបើមាន):..............................................................................

ខ្ញុំសូមធានាអះអាងចំពោះព័ត៌មានខាងលើ ពិតជាត្រឹមត្រូវ។

ធ្វើនៅ....................ថ្ងៃទី...............ខែ...............ឆ្នាំ២០..........
ហត្ថលេខា/ស្នាមមេដៃសាមីខ្លួន

គំរូ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## បញ្ជីឈ្មោះមន្ត្រីជាប់កិច្ចសន្យានិងបុគ្គលិកអណ្តែត ឆ្នាំ២០១៥

**ក្រសួង/ស្ថាប័ន**......................................................................................

| ល.រ | គោត្តនាម និងនាម | ភេទ | ថ្ងៃខែឆ្នាំកំណើត | អង្គភាពបំពេញការងារ | ចំណាត់ថ្នាក់មុខងារ | បរិយាយមុខងារ | រយៈពេលបម្រើការងារ ចាប់ពីថ្ងៃខែឆ្នាំដល់ថ្ងៃខែឆ្នាំ | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| ១ | | | | | | | | |
| ២ | | | | | | | | |
| ៣ | | | | | | | | |
| ៤ | | | | | | | | |
| ៥ | | | | | | | | |

- បញ្ឈប់បញ្ជីត្រឹមចំនួន : ...............នាក់( សរសេរជាអក្សរ.......................................... )

ខ្ញុំសូមធានាថា ព័ត៌មានដែលបានអះអាងខាងលើ ពិតជាត្រឹមត្រូវប្រាកដមែន។

ធ្វើនៅ..................ថ្ងៃទី.............ខែ.............ឆ្នាំ២០........

**ប្រធានអង្គភាពគ្រប់គ្រងផ្ទាល់**

* ចំណាត់ថ្នាក់មុខងារ ជាប្រភេទមុខងារដែលមានកំណត់ក្នុងសារាចរណែនាំលេខ០០១ សហវ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១០ ស្តីពីការប្រើប្រាស់និងការផ្តល់ប្រាក់កម្រៃសម្រាប់មន្ត្រីជាប់កិច្ចសន្យានិងបុគ្គលិកអណ្តែត